ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ :...៤៥០.....អយក.ប្រក

# ប្រកាស

## ស្តីពី

## បទបញ្ជាជ្រើសរើសនិស្សិតអោយចូលរៀននៅក្នុងគ្រឹះស្ថានឧត្តមសិក្សា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត. ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម. ០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- យោងប្រកាស លេខ ០១ អ.វ.ចតប្រ. ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៨៥ ស្តីពី បទបញ្ជាជ្រើសរើសនិស្សិតអោយចូលរៀន នៅក្នុងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សា ឯកទេស ក្នុងប្រទេស និង ទៅសិក្សានៅបរទេស
- យោងលិខិតលេខ ៨២៤ សជណអ.រ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០២ របស់រាជរដ្ឋាភិបាល ស្តីពី ការយកលទ្ធផលពិន្ទុនៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ សំរាប់ការជ្រើសរើស និង

ការប្រលងជ្រើសរើស សិស្ស និស្សិត ចូលរៀនគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេសក្នុងប្រទេស និង ទៅសិក្សានៅបរទេស

## សំរេច

ប្រការ ១ : គ្រឹះស្ថានឧត្តមសិក្សានីមួយៗ ត្រូវកំណត់ចំនួនជ្រើសរើសនិស្សិតអោយចូលរៀន អោយបានសមស្រប តាមនិយាមគរុកោសល្យ ។ ចំនួននេះ ត្រូវមាន ការឯកភាពយល់ព្រម ពីក្រសួងអាណាព្យាបាល ។ ការជ្រើសរើស ក៏ត្រូវយកចិត្តទុកដាក់ ចំពោះនិស្សិតក្រីក្រ និស្សិត មកពីតំបន់ដាច់ស្រយាល និង នារីភេទ ។

ប្រការ ២ : បេក្ខជនអាហារូបករណ៍ម្នាក់ៗ ដែលមានព្រឹត្តិប័ត្រពិន្ទុ អាចដាក់សំណុំពាក្យសុំចូលរៀនបានយ៉ាងច្រើនគ្រឹះស្ថានសិក្សាពីរ ដោយក្នុងនោះ មានបញ្ជាក់ពីគ្រឹះស្ថានសិក្សា ជាអាទិភាពទី១ និង អាទិភាពទី២ ។ បេក្ខជនមួយ នាក់ អាចបានទទួល អាហារូបករណ៍ តែមួយកន្លែង សំរាប់ការសិក្សា ក្នុងឆ្នាំសិក្សានីមួយៗ ។

ប្រការ ៣ : សិស្សពូកែ ទូទាំងប្រទេសប្រចាំឆ្នាំ ផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និង រូបវិទ្យា ដែលបានប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិត្រូវបាន អនុញ្ញាតអោយបានទទួលអាហារូបករណ៍ ចូលរៀនតាមគ្រឹះស្ថានឧត្តមសិក្សា ទៅតាមជំនាញ ពូកែរបស់ខ្លួន ។ សិស្សពូកែទាំងនេះត្រូវមកដាក់ពាក្យ សុំចូលរៀននៅនាយកដ្ឋានឧត្តមសិក្សា ។

ប្រការ ៤ : ការជ្រើសរើសនិស្សិតអោយចូលរៀន មុខជំនាញនានា លើកលែង មុខជំនាញ ភាសាបរទេស សារគមនាគមន៍ និង សិល្បៈ នៅតាមគ្រឹះស្ថានឧត្តមសិក្សាមានពីររូបភាព :

- រូបភាពទី១ : ធ្វើការជ្រើសរើស ចំពោះបេក្ខជន ដែលមានព្រឹត្តិប័ត្រពិន្ទុ នៅពេលប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ។ ការជ្រើសរើសនេះ ធ្វើឡើងដោយផ្អែកលើនិទ្ទេសនៃមុខវិជ្ជាប្រលង និង ចំណាត់ថ្នាក់ របស់បេក្ខជន ។ ការជ្រើសរើស ក្នុងរូបភាពទី ១ អនុវត្តសំរាប់ជ្រើសរើស និស្សិតអាហារូបករណ៍ និង និស្សិតសិក្សាបង់ថ្លៃ ។ ចំនួននិស្សិតអាហារូបករណ៍ ត្រូវបែងចែក សំរាប់អ្នកពូកែ អ្នកក្រីក្រ អ្នករស់នៅតំបន់ដាច់ស្រយាល និង នារីភេទ ។

- រូបភាពទី២ : ធ្វើការជ្រើសរើសដោយឆ្លងកាត់ការប្រលងប្រជែង ចំពោះបេក្ខជនដែលពុំមានព្រឹត្តិប័ត្រពិន្ទុ ( បេក្ខជនជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិមុនឆ្នាំ២០០២ ) ។

ប្រការ ៥ : ចំពោះមុខជំនាញ ដែលទាមទារសម្បទា រឺ ឧបនិស្ស័យខាងវិជ្ជាជីវៈ ដូចជា ភាសាបរទេស សារគមនាគមន៍ និង សិល្បៈ ការជ្រើសរើស ធ្វើឡើង ដូចខាងក្រោម :

- រូបភាពទី១ : ជ្រើសរើសដោយផ្អែកលើព្រឹត្តិប័ត្រពិន្ទុ នៅពេលប្រលងយកសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិនូវ មុខវិជ្ជាចំណេះទូទៅ និង ធ្វើការប្រលងនូវ មុខវិជ្ជាជំនាញ មួយ រឺ ពីរ មុខវិជ្ជា ( ភាសា . សិល្បៈ ) ។
- រូបភាពទី២ : ធ្វើការប្រលងជ្រើសរើស ទាំងមុខវិជ្ជា ចំណេះទូទៅ និង ជំនាញ ចំពោះបេក្ខជនជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ មុនឆ្នាំ ២០០២ ។

ប្រការ ៦ : ក- មុខវិជ្ជាដែលត្រូវកំណត់យកជាមូលដ្ឋាន សំរាប់ការជ្រើសរើស ក្នុងរូបភាពទី១ និង រូបភាពទី ២ នៃប្រការ ៤ តាមមុខជំនាញឯកទេសនីមួយៗ មិនអោយលើសពី ៣មុខវិជ្ជាឡើយ ។

ខ- ការកំណត់ អាយុបេក្ខជន កំណត់ ប្រភេទមុខវិជ្ជា កំណត់ និទ្ទេស និង កំណត់ ចំណាត់ថ្នាក់ សំរាប់ការជ្រើសរើស និងការប្រលងប្រជែងជាសិទ្ធិរបស់គ្រឹះស្ថានសិក្សា នីមួយ ៗ ។

ប្រការ ៧ : បេក្ខជនដែលមានព្រឹត្តិប័ត្រពិន្ទុ ហើយពុំបានសិក្សាក្នុងគ្រឹះស្ថានឧត្តមសិក្សាក្នុងឆ្នាំ នេះអាចដាក់ពាក្យ សុំអោយធ្វើការជ្រើសរើសចូលរៀននៅឆ្នាំក្រោយ១ទៀតបាន ។ ចំពោះបេក្ខជនដែលជាប់សញ្ញា ប័ត្រមធ្យមសិក្សាទុតិយភូមិមុនឆ្នាំ ២០០២ មានសិទ្ធិប្រលងយកអាហារូបករណ៍ចូលរៀននៅក្នុង គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ តែក្នុងឆ្នាំ ២០០២នេះ ប៉ុណ្ណោះ ប៉ុន្តែមានសិទ្ធិដាក់ពាក្យសុំ ប្រលងចូលរៀនក្នុងប្រភេទបង់ថ្លៃសិក្សា នាឆ្នាំនេះ និង ឆ្នាំក្រោយ១ទៀតបាន ។

ប្រការ ៨ : ក- ការជ្រើសរើសនិស្សិត រូបភាពទី ១ ដូចក្នុងប្រការ ៤ ធ្វើឡើង ក្រោយពីគ្រឹះស្ថានសិក្សានីមួយៗ បានទទួលបញ្ជីឈ្មោះបេក្ខជន ដែលបានប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ដែល ក្នុងនោះ មានបញ្ជាក់ពី និទ្ទេសតាមមុខវិជ្ជា និង ចំណាត់ថ្នាក់ ពីនាយកដ្ឋានឧត្តមសិក្សា ។

ខ- ការប្រលងជ្រើសរើសនិស្សិតរូបភាពទី ២ ដូចក្នុងប្រការ ៤ មាន ២ ប្រភេទ :

ប្រភេទ ទី១ : ប្រលងជ្រើសរើសនិស្សិតអាហារូបករណ៍ដែលប្រព្រឹត្តទៅនៅដើម ខែ កក្កដា ឆ្នាំ ២០០២ ។

ប្រភេទ ទី២ : ប្រលងជ្រើសរើសនិស្សិតបង់ថ្លៃសិក្សាមាន ២ ដង អនុវត្តចំពោះគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និង ឯកជន នឹងប្រព្រឹត្តទៅបន្ទាប់ពីការប្រលងជ្រើសរើសនិស្សិតអាហារូបករណ៍ ។

ប្រការ ៩ : ក្រសួង អប់រំ យុវជន និង កីឡា ត្រូវធ្វើការផ្សព្វផ្សាយ ដំណឹងជ្រើសរើសរួមអោយបានទូលំទូលាយ និង គ្រឹះស្ថានឧត្តមសិក្សានីមួយ ៗ ត្រូវធ្វើការផ្សព្វផ្សាយលំអិត ពីដំណឹងនៃការជ្រើសរើសរបស់ខ្លួន ។

ប្រការ ១០ : ចាប់ពីថ្ងៃប្រកាសផ្សាយដំណឹងបេក្ខជនម្នាក់ៗត្រូវមកដាក់សំណុំលិខិតផ្ទាល់ខ្លួននៅតាមគ្រឹះស្ថានសិក្សាដែលខ្លួនចង់រៀន ហើយសំណុំលិខិតនោះមាន :

- ពាក្យសុំចូលរៀននៅក្នុងគ្រឹះស្ថានឧត្តមសិក្សា ចំនួន ០១ ច្បាប់
- ប្រវត្តិរូបដែលមានបិទរូបថត (៤ គុណ ៦ ស.ម) ចំនួន ០២ ច្បាប់
  (ចំពោះបេក្ខជនមានព្រឹត្តិប័ត្រពិន្ទុ ប្រវត្តិរូបត្រូវមានការបញ្ជាក់ពីនាយកសាលា)
- សញ្ញាប័ត្រ រឺ វិញ្ញាបនប័ត្របញ្ជាក់ថាបានប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ
  (ចំពោះបេក្ខជនមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ មុនឆ្នាំ ២០០២)និងព្រឹត្តិប័ត្រពិន្ទុនៃការប្រលង សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិចំពោះបេក្ខជនមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិចាប់ពីឆ្នាំ ២០០២ ចំនួន ០១ ច្បាប់ចេញអោយដោយនាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ
- រូបថតក្នុងពេលថ្មី ទំហំ (៤ គុណ ៦) ចំនួន ៣ សន្លឹក

ចំពោះបេក្ខជនដែលមានស្ថានភាពគ្រួសារក្រីក្រ និង អ្នករស់នៅតំបន់ដាច់ស្រយាល ហើយចង់បានអាទិភាពទទួលអាហារូបករណ៍ ត្រូវមាន ឯកសារពីរច្បាប់ថែមទៀតគឺ :

- សេចក្តីបញ្ជាក់ត្រឹមត្រូវពីរដ្ឋអំណាចថ្នាក់ឃុំ សង្កាត់ អំពីភាពក្រីក្រ និងអាស័យដ្ឋានរស់នៅតំបន់ដាច់ស្រយាល ។
- ប័ណ្ណគ្រួសារថតចំលងតាមផ្លូវច្បាប់ ០១ ច្បាប់ ។

ប្រការ ១១ : បេក្ខជនដែលផ្តល់ពតិមានមិនត្រឹមត្រូវ ក្លែងបន្លំ នៅក្នុងសំណុំលិខិតផ្ទាល់ខ្លួននៅពេលដាក់ពាក្យសុំចូលរៀនត្រូវលុបឈ្មោះចេញពីបញ្ជីបេក្ខជន ។ ក្នុងករណីរកឃើញនៅក្រោយ ពេលចូលរៀននោះ ត្រូវលុបឈ្មោះ ចេញពីបញ្ជីនិស្សិត ហើយ ប្រសិនបើបានប្រលងបញ្ចប់ការសិក្សាជាប់ ក្រសួងមិនប្រគល់សញ្ញាប័ត្រអោយឡើយ ។

ប្រការ ១២ : ចំពោះការជ្រើសរើសនិស្សិតអាហារូបករណ៍ ដូចក្នុង រូបភាពទី ១ នៃប្រការ៤គ្រឹះស្ថានសិក្សានីមួយៗ ត្រូវបង្កើតគណៈកម្មការជ្រើសរើសមួយ ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១-នាយកគ្រឹះស្ថានសិក្សា | ជាប្រធាន |
| ២-តំណាងក្រសួងអប់រំ យុវជន និង កីឡា មួយរូប | ជាអនុប្រធាន |

៣-តំណាងក្រសួងដែលជាអាណាព្យាបាល មួយរូប ជាអនុប្រធាន
៤-នាយករងទទួលបន្ទុកការសិក្សា មួយរូប ជាសមាជិក
៥-ព្រឹទ្ធបុរសមហាវិទ្យាល័យដែលមានការជ្រើសរើសនិស្សិត ជាសមាជិក
៦-ប្រធានការិយាល័យសិក្សា មួយរូប ជាសមាជិក និង ជាលេខា ។

គណៈកម្មការនេះ តែងតាំងដោយក្រសួងអាណាព្យាបាល និង ធ្វើការជ្រើសរើស ដោយផ្អែកលើគោលការណ៍ឯកភាព និង តាមចំនួនដែលបានកំណត់ ។ ក្នុងករណី ជ្រើសរើសបេក្ខជនមិនគ្រប់តាមចំនួន និង តាមលក្ខខណ្ឌកំណត់ គណៈកម្មការជ្រើសរើស អាចបញ្ចុះនិទ្ទេស រឺ បញ្ចុះចំណាត់ថ្នាក់ក្នុងក៏រិតសមស្រប ដើម្បីធ្វើការជ្រើសរើសបន្ថែម អោយបានគ្រប់ចំនួនកំណត់ ។

គណៈកម្មការជ្រើសរើស អាចស្នើសុំបង្កើត អនុគណៈកម្មការ ផ្សេង ១ ទៀត ជាជំនួយការក្នុង ការរៀបចំឯកសារ សំរាប់ការជ្រើសរើស ។

ប្រការ ១៣ : នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅត្រូវផ្តល់លទ្ធផលនៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ( បញ្ជីឈ្មោះសំរង់និទ្ទេសតាមមុខវិជ្ជា និងចំណាត់ថ្នាក់របស់បេក្ខជន ) មកនាយក - ដ្ឋានឧត្តមសិក្សា អោយបានមួយសប្តាហ៍យ៉ាងយូរក្រោយការប្រកាសលទ្ធផលប្រលង និង ត្រូវផ្តល់ព្រឹត្តប័ត្រពិន្ទុរបស់បេក្ខជនម្នាក់ៗ អោយទៅបេក្ខជនសំរាប់ភ្ជាប់នៅក្នុងសំណុំពាក្យសុំចូលរៀន

ប្រការ ១៤ : នាយកដ្ឋានឧត្តមសិក្សា មានភារកិច្ច :

១-សំរបសំរួលគ្រប់គ្រឹះស្ថានឧត្តមសិក្សា ដែលធ្វើការជ្រើសរើសនិងធ្វើការប្រលងជ្រើសរើស ។
២-ផលិតបន្ថែមបញ្ជីឈ្មោះ សំរង់និទ្ទេសតាមមុខវិជ្ជា និង ចំណាត់ថ្នាក់របស់បេក្ខជន ដើម្បីចែកជូន គ្រប់គ្រឹះស្ថានឧត្តមសិក្សាដែលធ្វើការជ្រើសរើស ។
៣-រៀបចំលិខិតបទដ្ឋាន និង យន្តការនៃការជ្រើសរើស ការប្រលងជ្រើសរើសអោយប្រព្រឹត្តទៅបានល្អមានប្រសិទ្ធភាព និង តំលាភាព ។

ប្រការ ១៥ : គណៈកម្មការនានា នៃការប្រលង យកសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ត្រូវមានសមាសភាពមន្រ្តី មកពី គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ នាយកដ្ឋានឧត្តមសិក្សា និងអង្គភាពពាក់ព័ន្ធចូលរួម ។

ប្រការ ១៦ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ១៧ : អគ្គនាយកដ្ឋានឧត្តមសិក្សា បច្ចេកទេសនិងវិជ្ជាជីវៈ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានដែលមានការពាក់ព័ន្ធ និង គ្រប់គ្រឹះស្ថានឧត្តមសិក្សា មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខា តទៅ ។

ភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០២

ជ.ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

ប៊ុក ចន

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- ក្រសួងសុខាភិបាល
- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
  "ដើម្បីជូនជ្រាបជាពត៌មាន"
- គ្រប់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង
- គ្រប់វិទ្យាល័យក្នុងរាជធានីភ្នំពេញ
- ដូចក្នុងប្រការ១៧ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ